អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ខាងមុខ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៤។

កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”) សម្រេចបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ ខណៈនៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិក៏បានចេញដីកាលើកលែងការចោទប្រកាន់ប្រឆាំង យឹម ទិត្យ (“ដីកាលើកលែងការចោទប្រកាន់”)។

អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ចំនួន ០៥ ប្រឆាំងនឹងដីកាដំណោះស្រាយពីរផ្ទុយគ្នា៖

(១) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩)។

(២) បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួន ០២ (ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩)។

(៣) បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩)។

(៤) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ (ចុះថ្ងៃទី០៥ ខែ0ធ្នូ ឆ្នាំ២០១៩)។

(៥) បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ (ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩)។

កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ អនុលោមតាមវិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានសម្រេចដោះស្រាយបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងបន្តដំណើរការនីតិវិធីដោយពុំចាំបាច់បើកសវនាការផ្ទាល់មាត់ឡើយ។

សាលដីការបស់អង្គបុរេជំនុំជម្រះនឹងដាក់ផ្សាយនៅលើគេហទំព័រ៖ www.eccc.gov.kh/

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាអ្នកនាំពាក្យ

ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

អ៊ីមែល៖ neth.pheaktra@eccc.gov.kh